# សាលាបឋមសិក្សា D. Newlin Fell

900 W. Oregon Avenue ◆ Philadelphia, PA 19148 ◆
ទូរស័ព្ទ៖ ២១៥-៤០០-៨២៦០ • ទូរសារ៖ ២១៥-៤០០-៨២៦១ • ទូរស័ព្ទដៃ៖ ២១៥-៨៥២-១៦១៦ ◆
oashe@philasd.org

Omahr Ashe
នាយកសាលា

ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧

ជូនចំពោះ មាតាបិតា និងអាណាព្យាបាល៖

ជាសាលា យើងមិនគ្រាន់តែទទួលខុសត្រូវការបង្រៀនសិស្សរបស់យើងនៅមុខវិជ្ជាសំខាន់ៗតែប៉ុណ្ណោះទេ។ វាជាការទទួលខុសត្រូវផ្នែកសីលធម៌របស់យើង ក្នុងការបង្រៀនសិស្សនូវ យុត្តិធម៌ សមធម៌ លក្ខណៈខុសគ្នារវាង ខុស និង ត្រូវ ព្រមទាំងបុគ្គលិកលក្ខណៈផ្សេងៗដែលអាចកសាង សហគមន៍ ទីក្រុង ជាតិ និង ពិភពលោក ទាំងមូល។

នៅសាលា Fell ភាពខុសប្លែកគ្នារបស់យើងដែលធ្វើឲ្យសាលារបស់យើងមានលក្ខណៈពិសេសប្លែកពីគេ។ ជាមួយព្រឹត្តិការណ៍ជាច្រើនដែលកើតមានឡើងនៅក្នុងទីក្រុង និងប្រទេសរបស់យើង ដែលមិនមែនជាគ្រឹះនៃស្មារតីសាមគ្គីភាព ក្រុមគ្រួសារនៃសាលា Fell នឹងប្រឈមមុខប្រឆាំងនឹងការ គម្រាមកំហែង និង ការរើសអើង។

នៅថ្ងៃសុក្រ ទី៣ ខែមីនា ឆ្នាំ២០១៧ សិស្ស និង បុគ្គលិក ទាំងអស់ នឹងកាន់ដៃគ្នាដើរជុំវិញអាគារសាលារបស់យើង ជាសញ្ញាបញ្ចាញនូវ កម្លាំង និង ការប្រឆាំងនឹងការរើសអើង។ សិស្ស និង បុគ្គលិក ទាំងអស់ នឹងជួបជុំគ្នានៅក្រៅអាគារនៅម៉ោង ១០:៤៥ ព្រឹក។ យើងនឹងចាប់ដៃគ្នាប្រហែលជា១៥នាទី (១១:០០)។ ស្វាគមន៍មាតាបិតាឲ្យចូលរួម។

បើសិនជាលោកអ្នកមានសំណួរ និង/ឬ ការបារម្ភអ្វី សូមទាក់ទងមកខ្ញុំតាមលេខទូរស័ព្ទខាងលើនេះ។

សូមអរគុណ
Omahr Ashe, នាយកសាលា

**«ឧត្តមភាពគឺជាអ្វីដែលយើងចង់បាន»**